# បេសកកម្មសិក្សាស្រាវជ្រាវស្តីពី «សមិទ្ធផលកសាងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១» ស្ថិតក្នុងខេត្តបាត់ដំបង ដោយថ្នាក់ដឹកនាំនិងមន្ត្រីនៃរាជបណ្ឌិត្យសភា កម្ពុជា ចាប់ពីថ្ងៃសុក្រ ២រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹង ថ្ងៃទី២២ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩



ផ្តែរទ្វារប្រាសាទឯកភ្នំ តួប៉មកណ្តាល អំពី «ចម្លាក់រឿងកូរសមុទ្រទឹកដោះ»

ចាប់ពីថ្ងៃសុក្រ ២រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២២ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ឯកឧត្តមបណ្ឌិត ជូ ច័ន្ទដារី អគ្គលេខាធិការរងនៃរាជបណ្ឌិត្យសភាកម្ពុជា បានដឹកនាំមន្ត្រីស្រាវជ្រាវ មានលោកបណ្ឌិត ចាន់ ប៊ុន្នី លេខាអចិន្ត្រៃយ៍ នៃវិទ្យាស្ថានវិទ្យាសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម និង លោក ហៀង លាងហុង ប្រធានផ្នែកវប្បធម៌វិទ្យានៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ បានចុះបេសកកម្មសិក្សាស្រាវជ្រាវអំពីសមិទ្ធផលដែលកសាងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១នៅក្នុងទឹកដីខេត្តបាត់ដំបង ដើម្បីផ្ទៀងផ្ទាត់និងពិនិត្យឡើងវិញនូវសមិទ្ធផលលេចធ្លោសំខាន់ៗបន្សល់ទុករហូតបច្ចុប្បន្ន៖ ១. លក្ខណៈរចនាបទសិល្បៈនិងស្ថាបត្យកម្មសំណង់ប្រាសាទ ២. បច្ចុប្បន្នភាពនៃការអភិរក្សនិងការគ្រប់គ្រង និង ៣. សក្តានុពលនៃប្រាសាទបុរាណក្នុងការប្រើប្រាស់សម្រាប់វិស័យទេសចរណ៍។

តាមប្រវត្តិសាស្ត្រនៅដើមសតវត្សទី១១ ក្រោយការប្រកួតប្រជែងប្រហែល៩ឆ្នាំ ព្រះបាទសូរ្យវរ្ម័នទី១ បានទទួលជ័យជម្នះលើគូប្រជែង គឺព្រះបាទជ័យវីរវរ្ម័ន។ ព្រះអង្គបានគ្រងរាជ្យជាស្តេចនៃកម្ពុជទេស ដោយគង់នៅរាជធានីយសោធរ (អង្គរ)។ គេអាចចាត់ទុកព្រះបាទសូរ្យវរ្ម័នទី១ ថាជាព្រះរាជាសំខាន់មួយអង្គក្នុងប្រវត្តិសាស្ត្រអង្គរ ហើយក៏ជាព្រះរាជាដែលគ្រងរាជ្យសម្បត្តិរហូតជិត៥០ឆ្នាំ (គ.ស.១០០២-១០៥០)។ ក្នុងរាជនេះ កម្ពុជទេសមានវិសាលភាពធំធេងជាងពេលមុនៗ រីឯឥទ្ធិពលកម្ពុជទេសនាពេលនោះក៏ផ្សព្វផ្សាយទៅហួសពីរាជអំណាចដែលព្រះបាទសូរ្យវរ្ម័នទី១បានកាន់កាប់ទៅទៀត។

ក្នុងការគ្រងអំណាចរាជសម្បត្តិដ៏យូរនោះ ព្រះបាទសូរ្យវរ្ម័នទី១បានបំពេញនូវបូជនីយកិច្ចដឹកនាំនិងគ្រប់គ្រងជាតិទៅតាមយុទ្ធសាស្ត្រដោយឡែកមួយរបស់ទ្រង់៖ ១. ការបង្រួបបង្រួមឱ្យមានឯកភាពផ្ទៃក្នុងនិងការគាំទ្រដោយភាពស្មោះភក្តីបំផុតពីមន្ត្រីកំពូលៗក្នុងរាជការនិងពីប្រជានុរាស្ត្រ ២. ការគោរពនិងអនុវត្តន៍គោលនយោបាយទឹកដោយបានស្ថាបនាបារាយណ៍មន្ទាកិណីឬកម្ពុជក្សតីចំ (បារាយខាងលិច ឬទឹកថ្លា) ដែលមានទំហំធំជាងគេបង្អស់នៅអង្គរដើម្បីពង្រីកវិសាលភាពកសិកម្មសម្រាប់ការពង្រឹងសេដ្ឋកិច្ចអង្គរ ៣. ការស្តារជួសជុលនិងសាងសង់បន្ថែមលើសំណង់ជារាសាស្ត្រព្រមទាំងប្រាសាទក្នុងរាជ្យមុនៗ និង ៤. ស្ថាបនាប្រាសាទធំៗទាំងនៅក្នុងរាជធានីនិងនៅតំបន់ភាគខាងលិច ខាងកើត និងភាគខាងត្បូងប្រទេស។ នេះជាការបង្ហាញពីការពង្រីកវាតរាជអំណាចរបស់ទ្រង់ឱ្យទៅដល់គ្រប់ទីកន្លែង។ នៅក្រោមរាជ្យនេះហើយដែលវិស័យកសិកម្មព្រមទាំងសហគមន៍មនុស្សបានរីកចម្រើនឡើងខ្លាំងនៅតំបន់ទឹកដីខេត្តបាត់ដំបងសព្វថ្ងៃ។ ការវាតទីនៃរាជអំណាចរបស់ព្រះបាទសូរ្យវរ្ម័នទី១ ក៏បានលាតសន្ធឹងហួសពីដែនដីនៃកម្ពុជទេសនាពេលនោះ ឆ្ពោះទៅដល់ភូមិភាគខាងជើងនៃប្រទេសថៃសព្វថ្ងៃផង។

បេសកកម្មសិក្សាស្រាវជ្រាវនៅក្នុងខេត្តបាត់ដំបងនាពេលនេះ គឺក្រុមស្រាវជ្រាវបានសិក្សាដល់ទីតាំងប្រាសាទបុរាណសំខាន់ៗដែលលេចធ្លោកសាងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ ដូចជា ១. ប្រាសាទឯកភ្នំ (នរេន្ទ្រគ្រាម «ភូមិរបស់ព្រះរាជា») ២. ប្រាសាទបាសែត ឬប្រសិទ្ធី (ស្រីជ័យក្សេត្រ «ដែនដីនៃជ័យជម្នះ»)។ ប្រាសាទទាំងពីរនេះត្រូវបានស្ថាបនាសម្រាប់តម្កល់សិវលិង្គ «ស្រីសូរ្យវប្ឫស្វរៈ» ជាលទ្ធិទេវរាជតំណាងរាជ្យរបស់ព្រះបាទសូរ្យវរ្ម័នទី១ និង ៣. ប្រាសាទស្នឹង។ ក្រៅពីស្នាដៃសំខាន់ៗទាំងនេះ ប្រាសាទបាណន់ដែលជាប្រាសាទដ៏សំខាន់មួយផ្តើមកសាងនៅក្នុងរជ្ជកាលនៃព្រះរាជាសោយរាជ្យបន្តពីព្រះបាទសូរ្យវរ្ម័នទី១ គឺព្រះបាទឧទយាទិត្យវរ្ម័នទី២ ជាបុត្រារបស់ព្រះបាទសូរ្យវរ្ម័នទី១ក៏បានសិក្សាបន្ថែមផងដែរ។

តាមការសិក្សាបឋមរបស់យើង ផ្អែកលើសមិទ្ធផលស្នាដៃធំៗជាច្រើន ដូចជា ប្រាសាទបុរាណ ប្រព័ន្ធជារាសាស្ត្រ សិលាចារឹកដែលចារឡើងតាំងពីមុនឡើងគ្រងរាជ្យនិងចារដោយព្រះរាជាក្រោយៗមកទៀតជាដើម គឺបានបង្ហាញថា រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ ជាសម័យកាលរុងរឿងខ្លាំងណាស់ ម្យ៉ាងរាជអំណាចនៃព្រះរាជាខ្មែរអង្គនេះលាតសន្ធឹងធំធេងនិងល្បីរន្ទឺទៅដល់ប្រទេសជិតខាងដទៃទៀតផង។ ទោះបីជាយ៉ាងណា រហូតមកដល់ពេលនេះ ព្រះកិត្តិនាមរបស់ទ្រង់ក៏មិនសូវបានគេស្គាល់ច្បាស់លាស់នៅឡើយ។ នៅក្នុងឯកសារប្រវត្តិសាស្ត្រជាច្រើនក៏មាននិយាយតិចតួច ហើយហាក់មិនទាន់មានភាពច្បាស់លាស់ ព្រមទាំងពុំទាន់មានឯកភាពគ្នាជាច្រើនចំណុចអំពីប្រវត្តិនៃព្រះបាទសូរ្យវរ្ម័នទី១នេះ។ ដូច្នេះ លទ្ធផលពីការសិក្សាស្រាវជ្រាវនេះនឹងត្រូវប្រើប្រាស់សម្រាប់ការវិភាគស្វែងយល់ឱ្យបានច្បាស់លាស់ ដើម្បីចងក្រងជាឯកសារប្រវត្តិសាស្ត្រថ្មីមួយអំពី «រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១» ដោយផ្អែកលើមូលដ្ឋានឯកសារប្រវត្តិសាស្ត្រ សិលាចារឹក រចនាបទសិល្បៈនិងស្ថាបត្យកម្ម ដែលបានផ្សព្វផ្សាយដោយអ្នកស្រាវជ្រាវជាតិ អន្តរជាតិ រួមនឹងលទ្ធផលនៃការសិក្សាថ្មីៗដែលកំពុងធ្វើឡើងនាពេលនេះ៕



ប្រាសាទបាសែត ឬ ប្រសិទ្ធី (ស្រីជ័យក្សេត្រ "ដែនដីនៃជ័យជម្នះ)



ប្រាសាទឯកភ្នំ (នរេន្ទ្រគ្រាម «ភូមិរបស់ព្រះរាជា»)



ប្រាសាទស្ទឹងខាងលិច (រូបខាងលើ) និង ប្រាសាទស្ទឹងខាងកើត (រូបខាងក្រោម

